## នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និងខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៨ ខែ សីហា ឆ្នាំ ២០១៥

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Aug-2016, 15:47
CMS/CFO: Sann Rada

### ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ និងឧបសម្ព័ន្ធសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់សហមេធាវីនាំមុខ ឲ្យមានការធ្វើសវនាការពិចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី D22/2732

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI
Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini YE

## I. សេចក្តីផ្តើម

1. ផ្អែកលើព័ត៌មានដែលទទួលបានថ្មីៗនេះពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) សូមស្នើសុំអោយមានការធ្វើសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ចំពោះដើមបណ្តឹងរដ្ឋប្បវេណី D22/2732 សម្រាប់ សវនាការស្តីពីព្យសនកម្មដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី (“សវនាការលើផលប៉ះពាល់”) ក្នុងវគ្គជំនុំជម្រះស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង (ហៅកាត់រួមគ្នាថា“វគ្គជំនុំជម្រះទីបួន”)។

## II. សាវតារនីតិវិធី

2. កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ សហមេធាវីនាំមុខបានបញ្ជាក់ជូនអំពីលទ្ធភាព និងស្ថានភាពសុខភាពល្អប្រសើររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលសហមេធាវីនាំមុខបានជ្រើសរើស និងរាយនាមនៅក្នុងបញ្ជីបណ្តោះអាសន្ននៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើឲ្យមកផ្តល់សក្ខីកម្មនាសវនាការលើផលប៉ះពាល់សម្រាប់វគ្គជំនុំជម្រះទីបួន។[1] សហមេធាវីនាំមុខទទួលបានចម្លើយតបពីជំនួយការច្បាប់នៃក្រុមមេធាវី**ការពារគ្មានព្រំដែន**ថា ដើមបណ្តឹងរដ្ឋប្បវេណី D22/2732 មានស្ថានភាពសុខភាពល្អប្រសើរ និងមានលទ្ធភាពអាចមកផ្តល់សក្ខីកម្មនៅចំពោះមុខជំនុំជម្រះបាន។[2]

3. នាថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ សហមេធាវីនាំមុខបានដាក់ជូននូវបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឲ្យមកផ្តល់សក្ខីកម្មនាសវនាការលើផលប៉ះពាល់ក្នុងវគ្គជំនុំជម្រះទីបួន[3] ជាមួយនិងកាលវិភាគ

---

[1] *សូមមើល* ឧបសម្ព័ន្ធ I អ៊ីម៉ែល ពីមន្ត្រីច្បាប់រង ជូនចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានចំណងជើងថា “FW: សុខភាព និងកាលវិភាគសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មលើផលប៉ះពាល់” ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦ នៅវេលាម៉ោង៩ និង៤០នាទី ព្រឹក។

[2] ឧបសម្ព័ន្ធ I អ៊ីមែលពីជំនួយការច្បាប់ ជូនចំពោះមន្ត្រីច្បាប់រង មានចំណងជើងថា “RE: សុខភាព និងកាលវិភាគសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មលើផលប៉ះពាល់” ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ នៅវេលាម៉ោង ៩ និង ៦ នាទី រសៀល។

[3] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវផ្តល់សក្ខីកម្មលើសវនាការលើផលប៉ះពាល់ និងព្យសនកម្មដែលបានទទួលរង (វគ្គជំនុំជម្រះទីបួន) ឯកសារលេខ **E315/1/6** ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ (“សារណាស្តីអំពីសវនាការលើផលប៉ះពាល់”)។

ដែលបានស្នើសម្រាប់សវនាការនេះដែលមានរយៈពេលពីរថ្ងៃ។[4] ដើមបណ្តឹងរដ្ឋប្បវេណី D22/2732 ត្រូវបានគ្រោងឲ្យមកផ្តល់សក្ខីកម្មដោយផ្ទាល់ក្នុងបន្ទប់សវនាការនាថ្ងៃទីពីរ ពោលគឺអាចចាប់ផ្តើមពីម៉ោង ១ និង ១៥ នាទី រសៀល។

4. ផ្អែកលើកាលវិភាគសវនាការលើកចុងក្រោយដែលបានជូនដំណឹងដោយអង្គជំនុំជម្រះកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ សវនាការលើផលប៉ះពាល់ត្រូវបានគ្រោងនឹងធ្វើនាថ្ងៃទី១២ និងទី១៥ ខែសីហា ឆ្នាំ២០១៦។[5]

## III. ការពិភាក្សា

5. ដោយអនុលោមតាមសារណាស្តីពីសវនាការលើផលប៉ះពាល់ សហមេធាវីនាំមុខទទួលបានព័ត៌មានតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា ដើមបណ្តឹងរដ្ឋប្បវេណី D22/2732 បានសម្តែងទុក្ខកង្វល់អំពីបញ្ហាសុខភាពដែលគាត់កំពុងជួបប្រទះ និងថាគាត់មិនអាចធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីផ្តល់សក្ខីកម្មបានឡើយ។[6] បច្ចុប្បន្ន ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះស្នាក់នៅក្នុងខេត្តមណ្ឌលគីរី ហើយបើផ្អែកលើព័ត៌មានស្តីពីការពិនិត្យសុខភាពដែលដើមបណ្តឹងរូបនេះបានបញ្ជាក់ជូនអង្គភាពគាំពារសាក្សី និងអ្នកជំនាញ រោគសញ្ញារបស់គាត់មិនអនុញ្ញាតឲ្យគាត់អាចអង្គុយបានយូរឡើយ។[7]

6. សហមេធាវីនាំមុខត្រូវបានជូនដំណឹងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា ទោះបីជាមានបញ្ហាសុខភាពដូច្នេះក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណី D22/2732 នៅតែមានបំណងមកផ្តល់សក្ខីកម្មនាសវនាការលើផលប៉ះពាល់ដដែល ក្នុងលក្ខខណ្ឌដែលថាស្ថានភាពសុខភាពរបស់គាត់នឹងមិន

---

[4] ឧបសម្ព័ន្ធសម្ងាត់ ក៖ កាលបរិច្ឆេទបណ្តោះអាសន្ន និងដែលបានស្នើឡើង សម្រាប់សវនាការលើព្យសនកម្មដែលបានទទួលរងវគ្គជំនុំជម្រះទីបួន ឯកសារលេខ **E315/1/6.1** ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ("កាលបរិច្ឆេទបណ្តោះអាសន្ន និងដែលបានស្នើឡើង")។

[5] អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង ជូនចំពោះភាគី មានចំណងជើងថា "សំណើរបស់ ក.ស.ព សុំពន្យាពេលសម្រាប់ការធ្វើសវនាការទៅលើឯកសារគន្លឹះ ដោយសារមានករណីសង្គ្រោះបន្ទាន់" ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ២ និង៤២នាទី រសៀល។

[6] ឧសម្ព័ន្ធ II អ៊ីម៉ែលពីមន្ត្រីរដ្ឋបាលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនចំពោះមន្ត្រីច្បាប់ជាន់ខ្ពស់ មានចំណងជើងថា "ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សយ សុខាន់ មិនអាចធ្វើដំណើបានទេ" ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦។

[7] *ដូចយោងខាងលើ*

ដុនដាបជាងនេះទេ។ សហមេធាវីនាំមុខបានសហការជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីពិភាក្សា និងពិចារណាលើលទ្ធភាពនៃការធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ព្រមទាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានជូនដំណឹងសហមេធាវីនាំមុខថា គាត់មានការពេញចិត្តចំពោះការធ្វើសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នេះ។

7. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចតាមសំណើសុំស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ដោយផ្អែកលើហេតុផលវ័យចាស់ជរា និងស្ថានភាពសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ការធ្វើដំណើររបស់គាត់ត្រូវចំណាយពេលច្រើន។[8] សហមេធាវីនាំមុខយល់ឃើញថា ការធ្វើសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នឹងអាចជួយសម្រួលឱ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះអាចផ្តល់សក្ខីកម្មបាន មិនតែប៉ុណ្ណោះអាចជួយសម្រួលដល់លក្ខខណ្ឌសុខភាពរបស់គាត់ដែលអាចប៉ះពាល់ដោយសារការធ្វើដំណើរឆ្ងាយផងដែរ។ សហមេធាវីនាំមុខយល់ឃើញថា ការផ្តល់សក្ខីកម្មរបៀបនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ការងារត្រៀមរៀបចំសវនាការរបស់ភាគីដទៃទៀតឡើយ។

8. ដោយយោងទៅលើហេតុផលដូចបានជម្រាបជូនខាងលើនេះ សហមេធាវីនាំមុខសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។

## IV. សំណើ

9. សហមេធាវីនាំមុខសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

---

[8] សេចក្តីបង្គាប់ទៅលើការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោទស្សន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1049 ឯកសារលេខ **E315/1/6/1** ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ២។ ការបង្គាប់របស់អង្គជំនុំជម្រះឱ្យមានការរៀបចំផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោទស្សន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-13 ឯកសារលេខ **E236/5/3/2** ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣។ សំណើសុំផ្តល់សក្ខីកម្មរបស់ TCCP-1 (Denise Affonco) ឯកសារលេខ **E236/1/1/1** ចុះថ្ងៃទី២១ ខេវិច្ឆិកា ឆ្នាំ២០១២ ទំព័រ ១។

ក) ទទួលយកសំណើសុំកែប្រែបែបផែននៃការស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី D22/2732 ដែលបានបញ្ជាក់នៅក្នុងកាលវិភាគបណ្ដោះអាសន្ន និងដែលបានស្នើ និង

ខ) បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញធ្វើការសម្របសម្រួល និងចាត់វិធានការចំបាច់នានាដើម្បីឱ្យដើមបណ្ដឹងរដ្ឋប្បវេណី D22/2732 អាចផ្ដល់សក្ខីកម្មពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍បាន។

សូមអង្គជំនុំជម្រះសាលាដំបូងមេត្តាទទួលយកសំណើនេះដោយក្ដីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៨ខែ សីហា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | រាជធានីភ្នំពេញ | |